**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ:...២៤៤៣ ស.ន.ណ

ថ្ងៃ.អង្គារ.១៣កើត.ខែ.អស្សុជ.........ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី..១៩.....ខែ..តុលា....ឆ្នាំ២០២១

**សូមជម្រាបជូន**

**លោកប្រធានក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប**

**លោកស្រីប្រធានក្រុមហ៊ុន ព្រីម៉ា អូស៊ីអេស ៦.ក**

**កម្មវត្ថុ**: ប្រកាសលុបចោលការដេញថ្លៃស្តីពីការផ្តល់សេវាសម្អាត និងអនាម័យទូទៅនៅរោងចក្រផលិតទឹកស្អាត និងស្ថានីយ៍បូមទឹកល្អក់និពេជ នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សម្រាប់រយៈពេល១ឆ្នាំ។

**យោង**: កំណត់ហេតុបើកឯកសារដេញថ្លៃ(លើកទី២) កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជម្រាបជូនលោក-លោកស្រីប្រធានក្រុមហ៊ុនមេត្តាជ្រាបថា៖ ដោយស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ នៅតែមិនថមថយ ជាពិសេសគឺមេរោគបម្លែងថ្មីប្រភេទ Delta ដែលមានអត្រាចម្លងខ្លាំង អាចប្រឈមជាមួយនឹងការចម្លងជាយថាហេតុ តាមរយៈការចេញ-ចូលរបស់កម្មករសម្អាតនៃក្រុមហ៊ុនផ្តល់សេវាខាងលើនេះ នៅតាមទីតាំងនីមួយៗ ដូចនេះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសូមប្រកាសលុបចោលការដេញថ្លៃស្តីពីការផ្តល់សេវាសម្អាត និងអនាម័យទូទៅនៅរោងចក្រផលិតទឹកស្អាត និងស្ថានីយ៍បូមទឹកល្អក់និពេជ នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សម្រាប់រយៈពេល១ឆ្នាំ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងជូនដំណឹងឡើងវិញនៅពេលក្រោយ ក្នុងករណីមានការណែនាំថ្មី។

ក្រុមហ៊ុនអាចដាក់ពាក្យដកប្រាក់កក់ធានាការដេញថ្លៃពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការចាប់ពីថ្ងៃប្រកាសនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីប្រធានក្រុមហ៊ុនមេត្តាជ្រាប និងអនុគ្រោះ។

សូមលោក-លោកស្រីប្រធានក្រុមហ៊ុនទទួលនូវការគោរពរាប់អានពីយើងខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

**ហ៊ឹម ណូរ៉ាឌីន**

ចម្លងជូន៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្ម

-អង្គភាពលទ្ធកម្ម

"ដើម្បីជ្រាបជាព័ត៌មាន"

-ឯកសារ-កាលប្បវត្តិ